ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២០០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ ផ្ទេរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ៦៧៥ សជណ.កធ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៥៤៥ សជណ.កធ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៧៨៧៩/៨០៦ កសក.គហ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ ៤០៥ សជណ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ២០៥៦ លទ ២០ អអក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០ របស់អាជ្ញាធរអគ្គិសនីកម្ពុជា
- លិខិតលេខ ៧៤០ សជណ.ឧរ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៧៩១៦ លស.អក.លខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ របស់អគ្គិសនីកម្ពុជា។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដូចខាងក្រោម÷

-ទីតាំងរដ្ឋបាលជលផល របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានដីទំហំ ៨ ១៣១ ម៉ែត្រក្រឡា និងសំណង់អគារចាស់ចំនួន ០៤ខ្នង ស្ថិតនៅដីឡូត៍លេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-ទីតាំងធ្វើការអាជ្ញាធរអគ្គិសនីកម្ពុជា ស្ថិតនៅដីឡូត៍លេខ០៨ ផ្លូវ ២៨២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានដីទំហំ ៧៦១ ម៉ែត្រក្រឡា។

-ទីតាំងដីអតីតស្ថានីយ៍បូមទឹករបស់អគ្គិសនីកម្ពុជា ស្ថិតនៅជាប់ព្រំប្រទល់ខណ្ឌឫស្សីកែវ និងខណ្ឌដូនពេញ រាជធានីភ្នំពេញ មានទំហំ ៤ ៨១៤ ម៉ែត្រក្រឡា។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតនៅក្រោមការចាត់ចែងតាមបែបបទ និងនីតិវិធីជាធរមាន ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងរដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ២ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ